ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៨៣០ សហវ.ប្រក

# ប្រកាស
# ស្តីពី
# វិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្ដីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធាន និងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុលោមតាមមាត្រា៩ និងមាត្រា២៣ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្ដីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**ប្រការ២.-**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពគ្របដណ្ដប់លើការអនុវត្តប្រាក់បេសកកម្ម ទាំងនៅក្នុងនិងក្រៅប្រទេស រួមទាំងការកំណត់សោហ៊ុយធ្វើដំណើរសម្រាប់បេសកកម្មក្នុងប្រទេស សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រកាសនេះ មិនអនុវត្តចំពោះទីប្រឹក្សា ឬជំនួយការ ដែលមានឋានៈបន្ថែមលើមុខងារក្រៅពីក្របខ័ណ្ឌ នៃរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីភូមិ ជំនួយការរដ្ឋបាលឃុំ/សង្កាត់ បុគ្គលិកអណ្ដែត និងបុគ្គលិកជាប់កិច្ចសន្យាដែលមិនមានការទទួលស្គាល់ជាផ្លូវការដោយក្រសួងមុខងារសាធារណៈ។

## ឧបសម្ព័ន្ធទី២

## សោហ៊ុយធ្វើដំណើរសម្រាប់បេសកកម្មក្នុងប្រទេស

**ប្រការ៤.-**

សោហ៊ុយធ្វើដំណើរសម្រាប់បេសកកម្មនៅក្នុងប្រទេស ត្រូវផ្ដល់ជូនជាសាច់ប្រាក់រៀល អាស្រ័យលើមធ្យោបាយធ្វើដំណើរ និងចម្ងាយ នៃការធ្វើដំណើរក្នុងការបំពេញបេសកកម្មនៅក្នុងប្រទេស។

ការជ្រើសរើសប្រើប្រាស់មធ្យោបាយធ្វើដំណើរណាមួយ ត្រូវសម្រេចដោយអនុលោមតាមគោលការណ៍វិចារណកម្មចំណាយនិងសន្សំសំចៃ។

**ប្រការ៥.-**

សោហ៊ុយធ្វើដំណើរ ត្រូវបានកំណត់ តាមមធ្យោបាយធ្វើដំណើរ ដូចខាងក្រោម÷

- ក្នុងករណីប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់រដ្ឋ ឬផ្ទាល់ខ្លួន សោហ៊ុយធ្វើដំណើរត្រូវផ្ដល់ជូនដូចខាងក្រោម÷
  - សាច់ប្រាក់ចំនួន ៨០ ០០០ (ប្រាំបីម៉ឺន) រៀលក្នុង ១០០ គីឡូម៉ែត្រ សម្រាប់ រថយន្តមួយគ្រឿង ឬ ២៥ ០០០ (ពីរម៉ឺនប្រាំពាន់) រៀល ក្នុង ១០០ គីឡូម៉ែត្រ សម្រាប់ទោចក្រយានយន្តមួយគ្រឿង
  - សោហ៊ុយធ្វើដំណើរត្រូវគណនាជាសាច់ប្រាក់ ទៅតាមចម្ងាយផ្លូវធ្វើដំណើរជាក់ស្ដែង តាមគោលការណ៍សមាមាត្រធៀបនឹងចំនួនដែលបានកំណត់ខាងលើនេះ។
- ក្នុងករណីប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ សោហ៊ុយធ្វើដំណើរត្រូវផ្ដល់ជូនតាមតម្លៃសំបុត្ររថយន្តក្រុង រថយន្តតាក់ស៊ី កាណូត ឬកប៉ាល់ ដែលធ្វើដំណើរតាមគោលដៅនៃការបំពេញបេសកកម្ម តាមចំនួនទឹកប្រាក់កត់ត្រាក្នុងវិក្កយបត្រ ឬឯកសារមានលក្ខណៈជាផ្លូវការ។ ការជ្រើសរើសមធ្យោបាយធ្វើដំណើរប្រភេទនេះ ត្រូវបានផ្ដល់ប្រាក់ឧបត្ថម្ភបន្ថែមចំនួន ២០ ០០០ (ពីរម៉ឺន) រៀលក្នុង ០១ នាក់ ដើម្បីសម្រួលការធ្វើដំណើរបន្តទៅកាន់គោលដៅបេសកកម្ម។
- ក្នុងករណីមិនអាចប្រើប្រាស់មធ្យោបាយធ្វើដំណើរទាំងពីរប្រភេទខាងលើ ការជួលរថយន្ត ឬជួលមធ្យោបាយធ្វើដំណើរសមស្រប សម្រាប់ការបំពេញបេសកកម្មដូចជា ការធ្វើអធិការកិច្ច ឬសវនកម្ម ការសិក្សាស្រាវជ្រាវ ការត្រួតពិនិត្យការដ្ឋានសំណង់នានា និងការចុះទៅកាន់ តំបន់គោលដៅដាច់ស្រយាល ត្រូវអនុលោមតាមលក្ខខណ្ឌ ដូចខាងក្រោម÷
  - រដ្ឋបាលរាជធានី ខេត្ត ខណ្ឌ ក្រុង និងស្រុក ត្រូវស្នើសុំគោលការណ៍ជាមុន ពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - រដ្ឋបាលឃុំ សង្កាត់ ត្រូវស្នើសុំការអនុម័តយល់ជាមុន ពីក្រុមប្រឹក្សារបស់ខ្លួន។

**ប្រការ៦.-**

ក្នុងករណីប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់រដ្ឋ ឬផ្ទាល់ខ្លួន សោហ៊ុយធ្វើដំណើរដូចមានចែងក្នុងប្រការ៥ ខាងលើ ត្រូវផ្តល់ជូន ដូចខាងក្រោម÷

- សម្រាប់មធ្យោបាយធ្វើដំណើរជារថយន្ត គឺរថយន្ត ០១ គ្រឿងសម្រាប់បេសកកម្មដែលមានសមាជិក អតិបរមាចំនួន ៤ នាក់។ ក្នុងករណីសំណល់នៃផលចែករវាងចំនួនអ្នកធ្វើដំណើរសរុបធៀបនឹងឯកតា (ចំនួន ៤ នាក់/រថយន្ត ០១ គ្រឿង) មានចំនួនពី ០១ នាក់ដល់ ០៣ នាក់ សោហ៊ុយធ្វើដំណើរ ត្រូវផ្តល់បន្ថែមដោយគិតស្មើនឹងមធ្យោបាយធ្វើដំណើរចំនួន ០១ គ្រឿងទៀត។
- សម្រាប់មធ្យោបាយធ្វើដំណើរជាទោចក្រយានយន្ត គឺទោចក្រយានយន្ត ០១ គ្រឿង សម្រាប់បេសកកម្មដែលមានសមាជិកអតិបរមាចំនួន ២ នាក់។ ក្នុងករណីសំណល់នៃផលចែករវាងចំនួនអ្នកធ្វើដំណើរសរុបធៀបនឹងឯកតា(ចំនួន ២ នាក់/ទោចក្រយានយន្ត ០១ គ្រឿង) មានចំនួន ០១ នាក់ សោហ៊ុយធ្វើដំណើរត្រូវផ្តល់បន្ថែមដោយគិតស្មើនឹងមធ្យោបាយធ្វើដំណើរចំនួន ០១ គ្រឿង ទៀត។
- គោលការណ៍ខាងលើនេះ ត្រូវបានលើកលែងចំពោះអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងប្រធានក្រុមប្រឹក្សារាជធានី ខេត្ត។

**ប្រការ៧.-**

ចំពោះការបំពេញបេសកកម្មក្នុងប្រទេស សោហ៊ុយធ្វើដំណើរតាមយន្តហោះ មិនត្រូវបានផ្តល់ជូនទេ។

## ជំពូកទី៣

## វិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស

### ផ្នែកទី១

### គោលការណ៍ទូទៅ

**ប្រការ៨.-**

ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស ត្រូវកម្រិតមិនឱ្យលើសពី ១០ (ដប់) ថ្ងៃ សម្រាប់មន្ត្រីម្នាក់ក្នុងមួយខែ។

**ប្រការ៩.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើវិចារណកម្មលើចំណាយប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស ដោយកាត់បន្ថយជាអតិបរមា នូវចំនួនបេសកកម្ម និងចំនួនថ្ងៃបេសកកម្មមិនចាំបាច់ ឬកម្រិតចំនួនមន្ត្រីបំពេញបេសកកម្ម អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើវិចារណកម្ម លើចំណាយប្រាក់បេសកកម្មក្រៅប្រទេស ដូចខាងក្រោម÷

- ប្រើប្រាស់ជើងហោះហើរត្រង់និងសន្សំសំចៃបំផុត
- កាត់បន្ថយសមាជិកឱ្យនៅចំនួនតិចបំផុត

- ស្នើសុំគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល តាមរយៈក្រសួងមហាផ្ទៃ ដើម្បីសុំឱ្យស្ថានទូត ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះចូលរួមជំនួស
- កក់សំបុត្រយន្តហោះឱ្យបានមុនពីចម្ងាយ ដើម្បីទទួលបានតម្លៃសំបុត្រថោកជាង និងគួរទិញសំបុត្រយន្តហោះពីក្រុមហ៊ុន ឬភ្នាក់ងារទេសចរណ៍ដែលមានការចុះបញ្ជីត្រឹមត្រូវ មានកេរ្តិ៍ឈ្មោះ និងស្នាដៃល្អ និងក្នុងតម្លៃប្រកួតប្រជែង ឬតម្លៃសមរម្យ។

**ប្រការ១០.-**

បេសកកម្មនៅក្នុងនិងក្រៅប្រទេស ដែលបានអនុវត្តក្នុងឆ្នាំ នៅមិនទាន់បានស្នើសុំទូទាត់ ត្រូវបានអនុញ្ញាតឱ្យទូទាត់រយៈពេលយ៉ាងយូរបំផុត ត្រឹមត្រីមាសទីមួយនៃឆ្នាំបន្ទាប់ ដោយប្រើប្រាស់ឥណទានថវិកាឆ្នាំថ្មី។ ហួសកាលកំណត់នេះ ក្នុងករណីមិនមានការពន្យល់ច្បាស់លាស់ពីមូលហេតុនៃការយឺតយ៉ាវ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត មាននីតិសម្បទាគ្រប់គ្រាន់ក្នុងការបដិសេធការទូទាត់ប្រាក់បេសកកម្ម នៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលរាជធានី ខេត្ត ខណ្ឌ ចំណែកឯ រតនាគាររាជធានី ខេត្ត មាននីតិសម្បទាគ្រប់គ្រាន់ក្នុងការបដិសេធការទូទាត់ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលក្រុង ស្រុក ឃុំ និងសង្កាត់។

ប្រាក់បេសកកម្មដែលត្រូវបានបុរេប្រទានរួច នៅតែមិនទាន់បានទូទាត់ជម្រះក្នុងឆ្នាំថវិកា ត្រូវទូទាត់នៅក្នុងត្រីមាសទីមួយនៃឆ្នាំបន្ទាប់ ដោយប្រើប្រាស់ឥណទានថវិកាឆ្នាំថ្មី។ ហួសកាលកំណត់នេះ អាណាប័កនៅតែត្រូវទទួលខុសត្រូវក្នុងការទូទាត់ជម្រះប្រាក់បេសកកម្មដែលបានផ្តល់បុរេប្រទានជូន ហើយឥណទានថវិកាឆ្នាំថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ នឹងត្រូវបានបង្កកតាមទំហំទឹកប្រាក់បុរេប្រទាននោះ ទុកសម្រាប់ការទូទាត់ជម្រះចំណាយ។

ការខកខាន ឬការយឺតយ៉ាវក្នុងការទូទាត់បុរេប្រទានប្រាក់បេសកកម្មតាមកាលកំណត់ ត្រូវជាកម្មវត្ថុនៃការចាត់វិធានការរឹតបន្តឹង នៃការផ្តល់បុរេប្រទានលើកក្រោយៗទៀត ព្រមជាមួយនឹងការទទួលខុសត្រូវដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី២

## វិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងប្រទេស

**ប្រការ១១.-**

ប្រាក់បេសកកម្ម ត្រូវផ្តល់ជូនសមាសភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់កិច្ចសន្យា ដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានបម្លាស់ទី ចេញពីរង្វង់ដែនដីនៃរាជធានី ឬ រង្វង់ដែនដីនៃឃុំ/សង្កាត់ នៃក្រុង/ស្រុក ដែលមានចម្ងាយចាប់ពី ២០ (ម្ភៃ) គីឡូម៉ែត្រឡើងទៅ តាមលក្ខខណ្ឌកំណត់ ដូចខាងក្រោម÷

- ផ្តល់ជូនប្រាក់ហោប៉ៅ ប្រាក់ហូបចុក និងសោហ៊ុយធ្វើដំណើរ

- ផ្តល់ជូនបន្ថែម នូវប្រាក់ស្នាក់នៅ ក្នុងករណីដែលការបម្លាស់ទី មានចម្ងាយលើសពី ៤០ (សែសិប) គីឡូម៉ែត្រ និងបេសកកម្មតម្រូវឱ្យមានការសម្រាកនៅពេលយប់ តាមការសម្រេចរបស់អាណាប័ក។

**ប្រការ១២.-**

ក្នុងករណីមានបេសកកម្មក្នុងប្រទេស លើសពីចំនួនថ្ងៃកំណត់ ដោយធានាថាគម្រោងចំណាយ ដែលបានស្នើពិតជាត្រឹមត្រូវទៅតាមប្រភេទថវិកា និងឥណទានទំនេរ ដែលមាននៅក្នុងសៀវភៅថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវអនុលោមតាមគោលការណ៍ ដូចខាងក្រោម÷

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ខណ្ឌ ក្រុង និងស្រុក ក្នុងនាមរដ្ឋបាលរាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក ត្រូវស្នើសុំគោលការណ៍ចំណាយមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីពិនិត្យពីភាពត្រឹមត្រូវនៃកម្មវត្ថុចំណាយ ភាពទំនេរនៃឥណទាន ការកត់ត្រាចំណាយ និងផ្តល់ទិដ្ឋាការធានាចំណាយ មុននឹងធ្វើការបើកផ្តល់ប្រាក់បេសកកម្ម។
- មេឃុំ ចៅសង្កាត់ ក្នុងនាមរដ្ឋបាលឃុំ សង្កាត់ ត្រូវស្នើសុំការអនុម័តយល់ព្រមជាមុនពីក្រុមប្រឹក្សារបស់ខ្លួន លើសំណើបេសកកម្មលើសពីចំនួនថ្ងៃកំណត់ ដោយមិនចាំបាច់ស្នើសុំទិដ្ឋាការធានាចំណាយជាមុនពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្តឡើយ។ ឯកសារលិខិតយុត្តិការនិងកំណត់ហេតុនៃអង្គប្រជុំពិភាក្សានិងអនុម័តយល់ព្រមរបស់ក្រុមប្រឹក្សា នឹងក្លាយជាកម្មវត្ថុនៃការពិនិត្យរបស់រតនាគាររាជធានី ខេត្ត នៅពេលដែលរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ អនុវត្តនីតិវិធីទូទាត់ប្រាក់បេសកកម្ម។

**ប្រការ១៣.-**

មុខចំណាយដែលមានរបបកំណត់ដូចមានចែងក្នុងមាត្រា៧ និងមាត្រា៨ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មិនតម្រូវឱ្យមានវិក្កយបត្រទេ ប៉ុន្តែ តម្រូវឱ្យភ្ជាប់នូវលិខិតបញ្ជាបេសកកម្ម និងទិដ្ឋាការធ្វើដំណើរដែលមានការបញ្ជាក់ពីអង្គភាពគោលដៅបេសកកម្ម ដែលជាមូលដ្ឋានអត្ថិភាពនៃចំណាយបេសកកម្ម។ ដោយឡែក ការទូទាត់សោហ៊ុយធ្វើដំណើរ ដោយមិនប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់រដ្ឋ ឬផ្ទាល់ខ្លួន និងចំណាយផ្សេងៗ តម្រូវឱ្យមានវិក្កយបត្រ ស្របតាមនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន។

ការទូទាត់ចំណាយបេសកកម្មនៅក្នុងប្រទេស ត្រូវគិតជាប្រាក់រៀល។

## ផ្នែកទី៣

## វិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្រៅប្រទេស

**ប្រការ១៤.-**

តំបន់និងក្រុមប្រទេស សម្រាប់ការកំណត់ប្រាក់បេសកកម្មក្រៅប្រទេស ដូចមានចែងក្នុងមាត្រា១២ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ត្រូវបានកំណត់លម្អិតនៅក្នុង

ឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ១៥.-**

ក្នុងករណីមានបេសកម្មក្រៅប្រទេស រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវអនុវត្តតាមវិធាននិងនីតិវិធីដូចខាងក្រោម÷

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ខណ្ឌ ក្រុង និងស្រុក ក្នុងនាមរដ្ឋបាលរាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក ត្រូវស្នើសុំទិដ្ឋាការធានាចំណាយជាមុនពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់ឯកសារពាក់ព័ន្ធគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីភាពចាំបាច់នៃបេសកកម្ម។ ប្រាក់បេសកកម្ម ដែលបានទទួលទិដ្ឋាការធានាចំណាយពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួច អាណាប័កអាចបោះផ្សាយអាណត្តិបើកប្រាក់ជារបបកំណត់ផ្តល់ជូនតែម្តង។ ក្រោយពេលត្រឡប់មកវិញ អ្នកចុះបេសកកម្មត្រូវបំពេញនិងផ្តល់ឯកសារលិខិតយុត្តិការគ្រប់គ្រាន់និងត្រឹមត្រូវ សម្រាប់ទូទាត់ជម្រះចំណាយតាមការជាក់ស្តែង។
- មេឃុំ ចៅសង្កាត់ ក្នុងនាមរដ្ឋបាលឃុំ សង្កាត់ ត្រូវស្នើសុំការអនុម័តយល់ព្រមជាមុនពីក្រុមប្រឹក្សារបស់ខ្លួន លើសំណើបេសកកម្មក្រៅប្រទេស ដោយមិនចាំបាច់ស្នើសុំទិដ្ឋាការធានាចំណាយជាមុនពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្តឡើយ។ អាណាប័ក អាចបោះផ្សាយអាណត្តិបើកប្រាក់ជារបបកំណត់សម្រាប់ផ្តល់ជូនតែម្តង ហើយបញ្ជូនទៅរតនាគារ រាជធានី ខេត្ត ដោយភ្ជាប់ជាមួយកំណត់ហេតុនៃអង្គប្រជុំពិភាក្សានិងអនុម័តយល់ព្រមរបស់ក្រុមប្រឹក្សា។ ក្រោយពេលត្រឡប់មកវិញ អ្នកចុះបេសកកម្មត្រូវបំពេញនិងផ្តល់ឯកសារលិខិតយុត្តិការគ្រប់គ្រាន់និងត្រឹមត្រូវ សម្រាប់ទូទាត់ជម្រះចំណាយតាមការជាក់ស្តែង។

**ប្រការ១៦.-**

ប្រាក់បេសកកម្ម អាចត្រូវបានអនុញ្ញាតឱ្យគ្រោងបន្ថែមចំនួនពីរថ្ងៃ គឺមុនមួយថ្ងៃ និងក្រោយមួយថ្ងៃនៃកម្មវិធីផ្លូវការ។ ក្នុងករណីដែលជើងហោះហើរត្រូវចេញដំណើរ និងត្រឡប់មកវិញលើសពីពីរថ្ងៃ ត្រូវតែមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់។

**ប្រការ១៧.-**

ក្នុងករណីមានការពន្យារពេលបំពេញបេសកកម្មក្រៅប្រទេស ដោយមូលហេតុសត្យានុម័ត ប្រាក់បេសកកម្ម អាចត្រូវបានផ្តល់ជូនបន្ថែម តាមលក្ខខណ្ឌ ដូចខាងក្រោម÷

- ត្រូវមានការយល់ព្រមពីប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត ចំពោះរដ្ឋបាលរាជធានី ខេត្ត ខណ្ឌ ក្រុង និងស្រុក
- ត្រូវមានការអនុម័តយល់ព្រមពីក្រុមប្រឹក្សា ចំពោះរដ្ឋបាលឃុំ សង្កាត់

- អាណាប័ក ត្រូវទទួលខុសត្រូវលើភាពត្រឹមត្រូវនៃលិខិតយុត្តិការចំណាយរបស់គណៈប្រតិភូ រួមទាំងរបាយការណ៍សម្រាប់ជាមូលដ្ឋាននៃការទូទាត់បន្ថែមនេះ។

**ប្រការ១៨.-**

មុខចំណាយទាំងឡាយណាដែលត្រូវបានទទួលរ៉ាប់រងពីភាគីអញ្ជើញ មិនត្រូវបានផ្តល់ជូនឡើយ។ ក្នុងករណីដែលរាល់មុខចំណាយទាំងអស់ ជាបន្ទុកទាំងស្រុងរបស់ភាគីអញ្ជើញ មានតែប្រាក់ហោប៉ៅ ប៉ុណ្ណោះដែលត្រូវផ្តល់ជូនជាប្រាក់បេសកកម្ម និងមានកម្រិតមិនលើសពី ១០(ដប់)ថ្ងៃ។

**ប្រការ១៩.-**

ប្រាក់ចំណាយលើវត្ថុអនុស្សាវរីយ៍ ត្រូវផ្តល់ជូនចំពោះបេសកកម្ម ដែលដឹកនាំដោយប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ឬអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាង ដើម្បីចូលរួមកិច្ចចរចាទ្វេភាគី ឬពហុភាគីតាមការប្រគល់សិទ្ធិរបស់រាជរដ្ឋាភិបាល។

ប្រាក់ចំណាយលើវត្ថុអនុស្សាវរីយ៍មិនត្រូវផ្តល់ជូនឡើយ ចំពោះបេសកកម្មផ្សេងទៀត ដូចជាការចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា ឬវគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា។

**ប្រការ២០.-**

រដ្ឋបាលថ្នាក់ជាតិ ត្រូវផ្តល់ជូនលិខិតយុត្តិការចំណាយផ្សេងៗដូចជា ឯកសារចម្លងនៃលិខិតឆ្លងដែនដែលមានបោះត្រាចេញចូលប្រទេសគោលដៅបំពេញបេសកកម្ម ប័ណ្ណឡើងជិះយន្តហោះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រោយពេលបញ្ចប់បេសកកម្មរួចយ៉ាងយូរត្រឹមរយៈពេល៣០ថ្ងៃ មករតនាគាររាជធានី ខេត្ត ដើម្បីរក្សាទុក។

ការទូទាត់ចំណាយបេសកកម្មក្រៅប្រទេស តម្រូវឱ្យមានវិក្កយបត្រ ចំពោះសោហ៊ុយធ្វើដំណើរនិងចំណាយផ្សេងៗប៉ុណ្ណោះ។ ចំពោះរាល់មុខចំណាយដែលមានរបបកំណត់ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មិនតម្រូវឱ្យមានវិក្កយបត្រទេ។

## ផ្នែកទី៤

## បទប្បញ្ញត្តិពិសេសសម្រាប់បេសកកម្មនៅតាមតំបន់ជាប់ព្រំដែន

**ប្រការ២១.-**

បេសកកម្មនៅតាមតំបន់ជាប់ព្រំដែន គឺការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានបម្លាស់ទីចេញពីរង្វង់ដែនដីនៃឃុំ សង្កាត់ ក្រុង ស្រុកដែលសាមីខ្លួនបំពេញការងារជាប្រក្រតី ដែលមានចម្ងាយចាប់ពី ២០(ម្ភៃ) គីឡូម៉ែត្រ ឡើងទៅ ចូលក្នុងដែនដីនៃប្រទេសថៃ ប្រទេសឡាវ ឬ ប្រទេសវៀតណាមក្នុងចម្ងាយមិនលើសពី ២០(ម្ភៃ) គីឡូម៉ែត្រ គិតពីព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២២.-**

វិធាននិងនីតិវិធី នៃការអនុវត្តប្រាក់បេសកកម្មនៅតាមតំបន់ជាប់ព្រំដែន ត្រូវអនុលោមតាមវិធាននិងនីតិវិធី នៃការអនុវត្តប្រាក់បេសកកម្មក្នុងប្រទេស ដូចមានចែងក្នុងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្ដីពីប្រាក់បេសកកម្ម នៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## ជំពូកទី៥

## បទប្បញ្ញត្តិដោយឡែក

**ប្រការ២៣.-**

ចំពោះអង្គភាពមូលដ្ឋានដែលជាខ្សែបណ្ដោយរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ ដែលប្រើប្រាស់ទោចក្រយានយន្ត ជាមធ្យោបាយធ្វើដំណើរបំពេញបេសកកម្ម សោហ៊ុយធ្វើដំណើរសម្រាប់ទោចក្រយានយន្ត ត្រូវគណនាតាមអត្រា ដូចបានកំណត់ក្នុងប្រការ៥ និងប្រការ៦ នៃប្រកាសនេះ។

## ជំពូកទី៦

## ទោសប្បញ្ញត្តិ

**ប្រការ២៤.-**

សមាសភាពក្រុមប្រឹក្សា មន្ត្រីរាជការសាធារណៈគ្រប់លំដាប់ថ្នាក់ រួមទាំងមន្ត្រីជាប់កិច្ចសន្យា ត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ដោយមិនគិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណី ចំពោះសកម្មភាពដែលបានប្រព្រឹត្ត ឬសមគំនិតក្នុងការប្រព្រឹត្ត ដូចខាងក្រោម÷

- ការក្លែងបន្លំលិខិតយុត្តិការចំណាយ និងលិខិតស្នាមផ្សេងៗ ក្នុងគោលបំណងទទួលបានប្រាក់បេសកកម្ម ដែលខ្លួនពុំមានសិទ្ធិទទួលតាមការកំណត់នៃប្រកាសនេះ
- ការបង្វែរ ឬកេងប្រវ័ញ្ចប្រាក់បេសកកម្ម ដើម្បីយកទៅប្រើប្រាស់ក្រៅពីការបំពេញបេសកកម្ម
- ការបង្កើនរយៈពេលបំពេញបេសកកម្ម និង/ឬ ចំនួនមន្ត្រីចុះធ្វើបេសកកម្ម ដែលខុសពីបេសកកម្មដែលបានអនុវត្តជាក់ស្ដែង
- ការបង្កើតបេសកកម្មដោយក្លែងបន្លំ ក្នុងគោលបំណងទទួលបានប្រាក់ឧបត្ថម្ភបន្ថែម
- ការទទួលបានប្រាក់បេសកកម្មតែមិនបានផ្ដល់ជូនសាមីមន្ត្រីរាជការសាធារណៈ ដែលត្រូវបំពេញបេសកកម្ម
- ការរារាំង ឬការព្យាយាមរារាំង ដល់ដំណើរការត្រួតពិនិត្យប្រក្រតីភាព នៃការអនុវត្តប្រាក់បេសកកម្ម។

**ប្រការ២៥.-**

អនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ទណ្ឌកម្មរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល រួមមាន ជាអាទិ៍÷

- ការស្ដីបន្ទោស

- ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ
- ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យនៅទំនេរគ្មានបៀវត្ស
- ការបន្ថយឋានន្តរស័ក្តិឬថ្នាក់
- ការដាក់ឱ្យចូលនិវត្តន៍មុនកំណត់
- ការបញ្ឈប់ពីការងារដោយបង្ខំ ឬការបណ្តេញចេញពីមុខតំណែងជាមន្ត្រីរាជការ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ២៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ២៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ